# របាយការណ៍ប្រចាំត្រីមាសទី ១ ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណជា ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ុំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប រួមមាន បុគ្គលិកសរុបចំនួន ៣៤ រូប ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥ ។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:

- **ខែមករា លោកប្រធានមន្ទីរ និងថ្នាក់ដឹកនាំមន្ទីរ ចូលរួមកិច្ចប្រជុំផ្សេងៗ ចំនួន ០៥ លើក រួមមាន÷** ប្រជុំពិនិត្យលទ្ធផលការងារនៃការអនុវត្តរបស់អនុគណៈកម្មការអន្តរក្រសួង ដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច នៅសាលាខេត្ត។ ប្រជុំពិភាក្សាការងាររបស់មន្ទីរអង្គភាពជុំវិញខេត្ត នៅសាលាខេត្ត។ ប្រជុំគណៈបញ្ជាការរដ្ឋបាលឯកភាពខេត្ត នៅសាលាខេត្ត។ ប្រជុំគណៈកម្មការហិរញ្ញប្បទានសុខាភិបាលប្រចាំត្រីមាសទី ០៤ ឆ្នាំ ២០១៥ នៅមន្ទីរសុខាភិបាលខេត្ត។ ប្រជុំសាមញ្ញលើកទី ២០ របស់ក្រុមប្រឹក្សាខេត្ត ឆ្នាំទី ២ អាណត្តិទី ២ នៅសាលប្រជុំសាលាខេត្ត។
- **ខែមករា លោកប្រធានមន្ទីរ ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីការិយាល័យ ចូលរួមក្នុងពិធីផ្សេងៗ ចំនួន ០៨ លើក ÷** ពិធីចែកអំណោយរបស់កាកបាទក្រហមកម្ពុជាខេត្តឧត្តរមានជ័យ នៅភូមិស្រះកែវ ឃុំពង្រ ស្រុកចុងកាល់។ សិក្ខាសាលាផ្សព្វផ្សាយ និងបូកសរុបលទ្ធផលការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំឆ្នាំ ២០១៥ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។ ពិធីសម្ពោធការតាំងពិពណ៌ ***"ភូមិមួយផលិតផលមួយ"*** រវាងខេត្តឧត្តរមានជ័យ និងខេត្តសុរិន្ទ្រ នៅបរិវេណសួនច្បារមុខស្នងការនគរបាលខេត្តឧត្តរមានជ័យ។ ពិធីសម្ពោធសាលាបឋមសិក្សាដងទង់ ស្ថិតនៅភូមិដងទង់ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៥ និងលើកទិសដៅការងារឆ្នាំ ២០១៦ របស់សាលា

ខេត្តឧត្តរមានជ័យ។ ពិធីបើកសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សាឆ្នាំ ២០១៤ -២០១៥ នៅមន្ទីរអប់រំ យុវជន និងកីឡា ខេត្តឧត្តរមានជ័យ។ សិក្ខាសាលាបូកសរុបសកម្មភាពការងារផ្លូវជនបទប្រចាំឆ្នាំ ២០១៥ និងទិសដៅការងារឆ្នាំ ២០១៦ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។ វគ្គបណ្តុះបណ្តាលវិធីសាស្ត្រអង្កេតស្តីពី ចំណេះដឹង ឥរិយាបថ និងការប្រតិបត្តិ នៅមជ្ឈមណ្ឌលសហប្រត្តបត្តិការ កម្ពុជា-ជប៉ុន រាជធានីភ្នំពេញ។

- **ខែកុម្ភៈ លោកប្រធានមន្ទីរ និងថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រី ចូលរួមកិច្ចប្រជុំផ្សេងៗ ចំនួន ០៧ លើក រួមមាន÷** ប្រជុំសាមញ្ញ លើកទី ២១ របស់ក្រុមប្រឹក្សាខេត្តឆ្នាំទី ២ អាណត្តិទី ២ នៅសាលាខេត្ត។ ប្រជុំត្រៀមទទួលបដិសណ្ឋារកិច្ច និងផែនការការពារសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** នៅសណ្ឋាគារ និងកាស៊ីណូ សាង៉ុំរីសត។ ប្រជុំក្រុមការងារថ្នាក់ជាតិប្រចាំខែមករា-កុម្ភៈ ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត នៅសាលាខេត្ត។ ប្រជុំបូកសរុបរបាយការណ៍អនុវត្តការងារប្រចាំឆ្នាំ ២០១៥ និងលើកទិសដៅបន្ត ឆ្នាំ ២០១៦ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅសាលាខេត្ត។ ប្រជុំពិភាក្សា ស្តីពីការគ្រប់គ្រងបញ្ជីវត្តមាននៅតាមអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។ ប្រជុំបូកសរុបរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១៥ និងទិស ដៅឆ្នាំ ២០១៦ នៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ (Red III) ខេត្តឧត្តរមានជ័យ។ ប្រជុំប្រចាំឆ្នាំ ២០១៥-២០១៦ ស្តីពីកិច្ចសហប្រត្តិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។
- **ខែកុម្ភៈ លោកប្រធានមន្ទីរ ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីការិយាល័យ ចូលរួមក្នុងពិធីផ្សេងៗ ចំនួន ០៧ លើក÷** ពិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៥ និងលើកទិលដៅការងារឆ្នាំ ២០១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលសន្និតចតុមុខ ភ្នំពេញ។ ពិធីចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៣ គ្រួសារ នៅភូមិថ្មល់កែង ឃុំអន្លង់វែង ស្រុកអន្លង់វែង។ វេទិកាសាធារណៈ នៅភូមិគោកស្ពាន ឃុំក្រសាំង ស្រុកចុងកាល់។ កម្មវិធីប្រកួតកីឡាសិស្សបឋម-មធ្យមសិក្សា ជ្រើសរើសជើងឯកថ្នាក់ខេត្ត នៅបហុកីឡាដ្ឋានខេត្តឧត្តរមានជ័យ។ សិក្ខាសាលាបញ្ចប់គម្រោងស៊ីសោមជំហាន ១ និងការដាក់ដំណើរការគម្រោងស៊ីសោមជំហាន២ (២០១៦-២០១៩) នៅសាលាខេត្ត។ ទិវាទីក្រុងស្អាត លើកទី ៤ ក្រោមប្រធានបទ ទីក្រុងខ្ញុំស្អាត សុខសុវត្ថិភាពល្អ ទេសចរណ៍មានកំណើន នៅបរិវេណច្រកអន្តរជាតិអូរស្មាច់។ ពិធីសម្ពោធសមិទ្ធផលឆ្លងក្លោងទ្វារ និងរបងវត្តរស្មីជ័យឧត្តមបេង នៅឃុំបេង ស្រុកបន្ទាយអំពិល។
- **ខែមីនា លោកប្រធានមន្ទីរ និងថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រី ចូលរួមកិច្ចប្រជុំផ្សេងៗ ចំនួន ០៤ លើក រួមមាន÷** ប្រជុំសាមញ្ញលើកទី ២២ របស់ក្រុមប្រឹក្សាខេត្ត ឆ្នាំទី ២ អាណត្តិទី ២ នៅសាលាខេត្ត។ ប្រជុំជាមួយគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ដើម្បីស្វែងយល់ពីការអនុវត្តច្បាប់ និងវិស័យយុត្តិធម៌ នៅសាលាខេត្ត។ កិច្ចប្រជុំក្រុមការងារពិសេសថ្នាក់ខេត្តសម្រាប់លុបបំបាត់ជម្ងឺគ្រុន

ចាញ់ខេត្ត នៅមន្ទីរសុខាភិបាលខេត្ត។ ប្រជុំពិភាក្សាលើការរៀបចំបញ្ជីរាយនាមមន្ត្រីរាជការការដែលត្រូវដំឡើងថ្នាក់ ការជ្រើសរើសមន្ត្រីរាជការក្របខណ្ឌឆ្នាំ ២០១៦ និងការគ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។

- **ខែមីនា លោកប្រធានមន្ទីរ ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីការិយាល័យ ចូលរួមក្នុងពិធីផ្សេងៗ ចំនួន ០៦ លើក÷** កម្មវិធីជួបជុំពិសារអាហារសាមគ្គី ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិ ០៨ មីនា ឆ្នាំ២០១៦ ខួបលើកទី ១០៥ ក្រោមអធិបតីភាព ឯកឧត្តម **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅភោជនីយដ្ឋានទន្លេបាសាក់ ២ រាជធានីភ្នំពេញ។ ពិធីចែកអំណោយមនុស្សធម៌ដល់ចាស់ជរាគ្មានទីពឹង អ្នកផ្ទុក និងអ្នកជម្ងឺអេដស៍ ជនពិការ ក្មេងកំព្រា មេម៉ាយទីទ័លក្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** នៅភូមិទួលត្បែង ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង និងភូមិបុរីរដ្ឋបាល សង្កាត់សំរោង ក្រុងសំរោង។ សន្និបាតរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត ប្រចាំឆ្នាំ ២០១៥ នៅសណ្ឋាគារឈើនប្រាក់កប ។ ពិធីអបអរសាទរទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៨ ឆ្នាំ ២០១៦ នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត។ ពិធីប្រកាសតែងតាំងមុខតំណែងប្រធានមន្ទីរកសិកម្មខេត្ត នៅសាលាខេត្ត។ កម្មវិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី ១០៥ ឆ្នាំ ២០១៦ ក្រោមប្រធានបទ វិនិយោគលើសមភាពយេនឌ័រដើម្បីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅសាលាស្រុកអន្លង់វែង។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- ចុះសហការជាមួយ ក្រុមការងាររបស់នាយកដ្ឋានផ្លូវលំជនបទ សិក្សាត្រួតពិនិត្យផ្លូវថែទាំខួបចំនួន ២ ខ្សែ ស្ថិតនៅឃុំជើងទៀន ស្រុកចុងកាល់ និងសង្កាត់កូនក្រៀល ក្រុងសំរោង សរុបប្រវែង ១៥,៥ គម ដើម្បីអនុវត្តន៍ក្នុងឆ្នាំ២០១៦
- ចុះរកទីតាំងគ្រួសក្រហមផ្គត់ផ្គង់ខ្សែផ្លូវ ពីភូមិគោកធ្នង់ ដល់ភូមិគោកត្រាង ឃុំជើនទៀន ស្រុកចុងកាល់ មានប្រវែងសរុប ៨.០០០ ម៉ែត្រ និងផ្លូវ ០១ ខ្សែទៀត នៅសង្កាត់កូនក្រៀល ក្រុងសំរោង មានប្រវែងសរុប ៧.៥០០ ម៉ែត្រ
- ចុះត្រួតពិនិត្យ និងសិក្សាគម្រោងផ្លូវជួសជុលបន្ទាន់ចាប់ផ្តើមពីភូមិគោកខ្ពស់ ដល់ភូមិថ្នល់ ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល សរុបប្រវែង ៣.៥០០ ម៉ែត្រ
- ចុះធ្វើផ្លាកផ្លូវគម្រោងថែទាំខួប ២០១៥ និងចាក់គ្រួសបំពេញក្បាលល្អ
- លោកប្រធានមន្ទីរ អមដំណើរគណៈប្រតិភូមកពីក្រសួងដឹកនាំដោយ ឯកឧត្តម **អ៊ិន ចន្ទា** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ចុះត្រួតពិនិត្យខ្សែផ្លូវថែទាំលក្ខណៈខួបឆ្នាំ ២០១៥ ដើម្បីបញ្ចប់សុពលភាព និង
- ចុះសិក្សា ត្រួតពិនិត្យខ្សែផ្លូវចាប់ពីភូមិគោកស្ពាន ដល់ភូមិរលំវែង ឃុំក្រសាំង ស្រុកចុងកាល់ មាន

ប្រវែងសរុប ៣.០៧០ ម៉ែត្រ ក្នុងនោះស្ពានត្រូវសាងសង់ថ្មី ចំនួន ០៤ កន្លែង និងសាងសង់លូថ្មី ចំនួន ០៦ កន្លែង។

**៣.២ ការខារផ្គត់ផ្គង់ទឹកស្អាត**

- ប្រជុំជាមួយគណៈកម្មការអភិវឌ្ឍន៍អភិឌ្ឍន៍ភូមិ និងសមាជិកក្រុមអ្នកប្រើប្រាស់ទឹកស្អាត និងអនាម័យ ស្តីពីការត្រួតពិនិត្យស្ថានភាពការប្រើប្រាស់ប្រភពទឹកស្អាត នៅភូមិអូរបាត់ដាវ សង្កាត់បន្ទាយរាក់ ក្រុងសំរោង
- ចុះត្រួតពិនិត្យប្រភពទឹកដែលប្រជាពលរដ្ឋប្រើប្រាស់ជាក់ស្តែង ក្នុងនោះមាន អណ្តូងស្នប់អាហ្វ្រីដេវចំនួន ០៤ អណ្តូង អណ្តូងលូចំនួន ០៨ អណ្តូង ទំនប់ទឹកចំនួន ០៤ កន្លែង ស្រះសហគមន៍ ០៣ កន្លែង
- ប្រជុំជាមួយមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត ស្តីពីស្ថានភាពកង្វះទឹកស្អាតប្រើប្រាស់តាមរយៈការផ្គត់ផ្គង់ និងចែកចាយតាមបណ្តាញប្រព័ន្ធទុយោទឹកស្អាតនៅសង្កាត់អូរស្វាច់ គ្រប់គ្រងដោយក្រុមហ៊ុន (L.Y.P Group)
- សាងសាង់ស្រះសហគមន៍ចំនួន ០២ កន្លែង នៅភូមិតាមាន់សែនជ័យ ឃុំគោកមន ០១ កន្លែង និងភូមិអូររំដួល ឃុំបេង ០១ កន្លែង ក្នុងស្រុកបន្ទាយអំពិល
- ចុះប្រជុំជ្រើសរើសទីតាំងសាងសង់អណ្តូងស្នប់អាហ្វ្រីដេវថ្មីចំនួន ០២ កន្លែង មានទីតាំងនៅភូមិពុរ ០១ កន្លែងនិងភូមិប៉ុរីរដ្ឋបាល ០១ កន្លែង និងជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវសម្រាប់ជួសជុល ១០ អណ្តូង នៅភូមិគោកជ្រេស ០២ អណ្តូង និង ភូមិកណ្តោក ០២ អណ្តូង ភូមិគោកចំបក់ ០២ អណ្តូង ភូមិត្របែក ០៣ អណ្តូង និងភូមិភ្លង់ចាស់ ០១ អណ្តូង ស្ថិតនៅសង្កាត់សំរោង ក្រុងសំរោង
- ចុះប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវថ្មីចំនួន ០៦ អណ្តូង នៅភូមិគោកវត្ត ០១ អណ្តូង ភូមិបន្ទាយចាស់ ០១ អណ្តូង ឃុំចុងកាល់ភូមិសែនមនោរម្យ ១ ចំនួន ០២ អណ្តូង និងភូមិសែនមនោរម្យ ២ ចំនួន ០២ អណ្តូង ឃុំគោកខ្ពស់
- ចុះប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់ចំនួន ០៩ អណ្តូង និងជ្រើសរើសគ្រួសារសម្រាប់ចែកចាយធុងចម្រុះ ១០០ គ្រួសារ នៅភូមិខ្នាចឬស្សី ០២ អណ្តូង និងធុងចម្រុះ៥០គ្រួសារ នៅភូមិគោកចាន់រី សង្កាត់បន្ទាយរាក់ ០២ អណ្តូង និងធុងចម្រុះ ៥០ គ្រួសារ ភូមិឈើក្រំ ០២ អណ្តូង និងភូមិបុស្សថ្មី ០២ អណ្តូង ក្នុងសង្កាត់កូនក្រៀល ក្រុងសំរោង និងភូមិថ្នល់បត់ ០១ អណ្តូង ក្នុងស្រុកអន្លង់វែង និង
- ចុះប្រជុំជ្រើសរើសទីតាំងស្រះសហគមន៍ និងចុះត្រួតពិនិត្យការងារសាងសង់ស្រះសហគមន៍ ០១ កន្លែងទំហំ (៤០មX៣០មX៣ម) នៅភូមិអូររំដួល ឃុំបេង ស្រុកបន្ទាយអំពិល សម្រេចបានលទ្ធផល ១០០ ភាគរយ ថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

### ៣.៣ ការងារថែទាំសុខភាពជនបទ

- ចូលរួមសន្និបាតសុខាភិបាលខេត្តឧត្តរមានជ័យលើកទី ១៣ និងការពិនិត្យរួមគ្នាសមិទ្ធិផលសុខាភិបាលឆ្នាំ ២០១៥ និងទិសដៅឆ្នាំ ២០១៦ នៅមន្ទីរសុខាភិបាលខេត្តឧត្តរាមានជ័យ។
- ចូលរួមកិច្ចប្រជុំប្រចាំត្រីមាសទី ៤ ឆ្នាំ ២០១៥ នៃការអនុវត្តកម្មវិធី CLTS នៅខេត្តតាកែវ។
- រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយការលើកកម្ពស់អនាម័យតាមរយៈស្ថានីយ៍វិទ្យុជាតិប្រាសាទតាមាន់ FM 90.00 MHz ចន្លោះពីម៉ោង 16:00pm-17:00pm ការផ្សាយគ្របដណ្តប់បានចំនួន ០៨ ស្រុក ០២ ខេត្ត (០៥ ស្រុក ក្នុងខេត្តឧត្តរមានជ័យ និង ០៣ ស្រុក ក្នុងខេត្តសៀមរាប)
- ប្រជុំស្តីពីការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យលើភូមិគ្រោង ODF ចំនួន០៣ឃុំ ០២ ស្រុក មានសិក្ខាកាមចូលរួមចំនួន ៣១ នាក់ ស្ត្រី ០៥ នាក់ នៅឃុំក្រសាំង ស្រុកចុងកាល់ និងសង្កាត់សំរោង ក្រុងសំរោង
- ចុះសិក្សា និងប្រមូលទិន្នន័យបង្គន់អនាម័យក្នុងភូមិគោលដៅ ១២ ភូមិ ០៣ ឃុំ ក្នុងស្រុកចុងកាល់ សម្រាប់គម្រោងឧបត្ថម្ភសម្ភារៈសាងសង់បង្គន់អនាម័យនៅតាមគ្រួសារចំនួន ៣០៣ បង្គន់ ជាផែនការឆ្នាំ ២០១៦ ។ ដោយមានការចូលរួមពីអាជ្ញាធរភូមិ និងប្រជាពលរដ្ឋសរុប ចំនួន ២៦១ នាក់ ស្ត្រី ចំនួន ១៤៤ នាក់
- សហការជាមួយមន្ត្រីនាយកដ្ឋាន ចុះសិក្សានិងវាយតម្លៃពីការប្រតិបត្តិអនុវត្តអនាម័យរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍ ជនបទ ក្នុងភូមិគោលដៅចំនួន ០២ ភូមិ ០២ ឃុំ និង ០២ ស្រុក ស្មើនឹង ៥១ គ្រួសារ គឺភូមិសាលាវាំង ឃុំគោកមន ស្រុកបន្ទាយអំពិល ២៤ គ្រួសារ និងភូមិចំការចេក សង្កាត់អូរស្មាច់ ក្រុងសំរោង មាន ២៧ គ្រួសារ និង
- ចុះធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញលើភូមិដែលបានបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងលើ ភូមិគោលដៅចំនួន ០៨ ភូមិ ស្ថិតក្នុងស្រុកចុងកាល់ ឃុំពង្រ មាន ០៣ ភូមិ និងក្រុងសំរោង សង្កាត់សំរោង មាន ០៥ ភូមិ។ មានការចូលរួមសហការពីអាជ្ញាធរឃុំ ភូមិ និងប្រជាពលរដ្ឋសរុបចំនួន ៧៥៦ នាក់ ស្ត្រី ៣៧១ នាក់ ក្នុងនោះកុមារចំនួន ១៣៤ នាក់ ។ ជាលទ្ធផល មានភូមិចំនួន ០៦ បានក្លាយទៅជាភូមិ ODF (ភូមិព្រៃនគរ ភូមិបន្ទាយជ័រ ឃុំពង្រ និងភូមិអូរឬស្សី ភូមិអូរក្រវ៉ាន់ ភូមិដូនកែន ភូមិឈូក)។

### ៣.៤ ការងារអភិវឌ្ឍន៍សហគមន៍

សហការជាមួយអង្គការ FH Cambodia ចុះសម្របសម្រួល និងជ្រើសរើសគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) បានចំនួន ០៨ ភូមិ គឺភូមិត្រពាំងប្រិយ៍ ភូមិទួលប្រសើរ ភូមិសុខសេរី ភូមិសំបូរ ភូមិទំនប់ថ្មី ភូមិស្រែល្អ ភូមិអូរត្រាច និងភូមិមានជ័យ ស្ថិតនៅក្នុងស្រុកត្រពាំងប្រាសាទ។

### ៣.៥ ការអភិវឌ្ឍន៍ព្រំដែនទិសខាងជើង និងខាងលិចប្រទេស

**ការងារសាងសង់ផ្ទះ÷** ភូមិតាមាន់សែនជ័យ បានសាងសរុបផ្ទះចំនួន ៣៩ខ្ន ង

- ផ្ទះសាងសង់សម្រេចបាន ១០០% ចំនួន ៣២ ខ្នង

- ផ្ទះសាងសង់សម្រេចបាន ៤០% ចំនួន ០៥ ខ្នង និង
- ផ្ទះសាងសង់សម្រេចបាន ៣០% ចំនួន ០២ ខ្នង។

## ៣.៦ ការិយាល័យអភិវឌ្ឍន៍ជនបទក្រុង/ស្រុក

- **ប្រធានការិយាល័យក្រុងសំរោង ចូលរួមក្នុងកិច្ចប្រជុំផ្សេងៗ ចំនួន ០៣លើក រួមមាន÷** ប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងស្តីពីវិធានផ្ទៃក្នុងរដ្ឋបាលក្រុងសំរោង។ ប្រជុំណែនាំដើម្បីកំណត់រៀបចំសំណើគម្រោងវិនិយោក្រុង។ ប្រជុំសាមញ្ញលើកទី ១៩ អាណត្តិទី ២ របស់ក្រុមប្រឹក្សាក្រុងសំរោង។
- **ប្រធានការិយាល័យស្រុកចុងកាល់ ចូលរួមក្នុងកិច្ចប្រជុំផ្សេងៗ ចំនួន ១០ លើក រួមមាន÷** ប្រជុំពិគ្រោះយោបល់លើសេច ក្តីព្រាងស្តីពីវិធានផ្ទៃក្នុងរដ្ឋបាលស្រុក។ វេទិកាសាធារណៈផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក និងចែកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួន ០៣ លើក នៅស្រុកចុងកាល់។ ចុះសិក្សាផ្លូវគោកស្ពាន និងរលំវែង មានប្រវែងសរុប ៣.២៧០ ម៉ែត្រ ស្ពាន ៤ កន្លែង លូ ៦ កន្លែង។ ចុះយកទីតាំងអណ្តូងស្នប់នៅមណ្ឌលសុខភាពចុងកាល់ និងការិយាល័យអប់រំ ស្រុកចុងកាល់។ ប្រជុំទទួលផែនការក្នុងមួយថ្ងៃមានសកម្មភាពអ្វីត្រូវផ្តល់ព័តិមានមកសាលាស្រុកចុងកាល់។ ប្រជុំប្រចាំខែ របស់គណៈកម្មការទទួលបន្ទុកស្ត្រីនិងកុមារ នៅសាលាស្រុកចុងកាល់។ ប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាស្រុកចុងកាល់ លើកទី ២១ អាណត្តិទី ២។ ចុះយកចំនួនស្រះសហគមន៍ទឹកស្អាតប្រើប្រាស់មិនកើត នៅតាមឃុំ ក្នុងស្រុកចុងកាល់។

## ៤. ទិសដៅការងារបន្ត

- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវចំនួន ១៧ អណ្តូង នៅក្រុងសំរោង ស្រុកបន្ទាយអំពិល ស្រុកចុងកាល់ ស្រុកត្រពាំងប្រាសាទ និងស្រុកអន្លង់វែង
- ជួសជុលអណ្តូងស្នប់អាហ្វ្រីដេវសម្រាប់ជួសជុលចំនួន ១០ អណ្តូង នៅក្រុងសំរោង ស្រុកបន្ទាយអំពិល ស្រុកចុងកាល់ ស្រុកត្រពាំងប្រាសាទ និងស្រុកអន្លង់វែង
- សាងសង់ធុងចម្រោះទឹកចំនួន ១០០ ធុង នៅក្រុងសំរោង ស្រុកបន្ទាយអំពិល ចុងកាល់ ត្រពាំងប្រាសាទ និងស្រុកអន្លង់វែង
- ចុះត្រួតពិនិត្យ និងសិក្សាផ្លូវជួសជុលបន្ទាន់ និងសាងសង់ថ្មី ទូទាំងខេត្ត សម្រាប់ការអនុវត្តក្នុងឆ្នាំ ២០១៦
- ចុះប្រមូលទិន្នន័យខ្សែផ្លូវថ្មី និងធ្វើបច្ចុប្បន្នភាព សម្រាប់ឆ្នាំ ២០១៦
- បន្តការសហការជាមួយអង្គការ FH Cambodia ដើម្បីចុះពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅតាមភូមិគោលដៅ ស្រុកត្រពាំងប្រាសាទ
- រៀបចំផែនការសកម្មភាពសម្រាប់ត្រីមាសទី២, ៣, ៤ ឆ្នាំ ២០១៦
- ចុះត្រួតពិត្យ និងសិក្សាខ្សែផ្លូវជួសជុលបន្ទាន់និងសាងសង់ថ្មី ទូទាំងខេត្ត សម្រាប់ការអនុវត្តក្នុង

ឆ្នាំ ២០១៦ និង

- ចូលរួមរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យជនបទ ជាមួយអង្គការដៃគូរ និងស្ថាប័នពាក់ព័ន្ធ។